ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល
សំណុំរឿងរដ្ឋប្បវេណីលេខ៖ ៨៥៤
ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩
សាលក្រមលេខ៖ ២០ (ណ)
ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្តាល

ចេញសាលក្រមដែលមានខ្លឹមសារដូចតទៅ៖

ដើមចោទឈ្មោះ [redacted] វណ្ណវិនីត ភេទស្រី អាយុ ៣៩ ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅ[redacted] ។

លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ មានការិយាល័យនៅ[redacted] ។

ចុងចម្លើយឈ្មោះ [redacted] ភេទប្រុស ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅ[redacted] ។

## អង្គហេតុ និងចំណុចវិវាទ

**១. សាលក្រមដែលទាមទារដោយដើមចោទ**

១.១. ប្តឹងសុំលែងលះប្តី

១.២. សុំសិទ្ធិគ្រប់គ្រងកូនទាំងបីនាក់ ១ឈ្មោះ [redacted] សុនិចាត់ ភេទប្រុស,ទី២ឈ្មោះ [redacted] សុជាតិ ភេទស្រី,ទី៣ឈ្មោះ [redacted] បញ្ញាស័ក្តិ ភេទប្រុស

១.៣ សុំបែងចែកទ្រព្យសម្បត្តិរួមប្តីប្រពន្ធជាពីរចំណែកស្មើគ្នា ដូចខាងក្រោម៖

ក.ដីមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០២០៦-០០៤៣ ដែលមានទីតាំងនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

ខ.ដីដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០២០៦-០០៦៧ ដែលមានទីតាំងនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

គ. ដីដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលវត្ថុលេខ ០៨០១០២០៦-០០៦៨ ដែលមានទីតាំងនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

ឃ.ដីដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលវត្ថុលេខ ០៨០១០២៨០៤-០៤៥៣ ដែលមានទីតាំងនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

ង.ដីដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលវត្ថុលេខ ០៨០១០២៨០៦-០១៤២ ដែលមានទីតាំងនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។



Scanned with CamScanner

៤.បំណុលរួមមានចំនួន ១៤៧.០០០ (ដប់បួនម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក ត្រូវទទួលខុសត្រូវពាក់កណ្តាលម្នាក់ ។

៥.បង្គាប់ឲ្យចុងចម្លើយប្រគល់នូវ ៖

ក.រថយន្តម៉ាក NEWFORD RANGER លេខតួ MNCUMFFSOKW941056 លេខម៉ាស៊ីន PSAT២៧៤៦០៩៣ ពណ៌ស ម៉ូដែលឆ្នាំ២០១៩ ។

ខ.គ្រឿងចក្រម៉ាក CAterpilar e120Bលេខតួ ៧MF-០៥៩៦៦ លេខម៉ាស៊ីន ០០៨៧៩៣ ពណ៌លឿង

គ.គ្រឿងចក្រម៉ាកអ៊ិច សេរីឆ្នាំ២០០៧ លេខតួ 4SG07333 ពណ៌លឿង ។

ឃ.គ្រឿងចក្រម៉ាកអ៊ិច សេរីឆ្នាំ២០០៧ លេខតួ 7NF01064 ពណ៌លឿង ។

ង.រថយន្តម៉ាក lexus ពាក់ស្លាកលេខ ភ្នំពេញ 2AT-៤៧៨៣ ពណ៌សសេរីឆ្នាំ២០០៥ ជាទ្រព្យដោយឡែករបស់ខ្លួន ។

**២. ការពន្យល់ត្រួសៗអំពីរឿងក្តី**

កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ ដើមចោទឈ្មោះ [redacted] វណ្ណវិទីត បានដាក់ពាក្យបណ្តឹងមកសាលាដំបូងខេត្តកណ្តាល ដោយស្នើសុំលែងលះពីចុងចម្លើយឈ្មោះ [redacted] កុសល ដោយអះអាងថា ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងចុងចម្លើយ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់ ។ ក្នុងការរស់នៅជាមួយគ្នាមានកូនចំនួន ០៣ នាក់ និងមានទ្រព្យសម្បត្តិរួម ទ្រព្យដោយឡែក និងបំណុលដូចមានក្នុងកម្មវត្ថុបណ្តឹងខាងលើ ។ ក្នុងការរស់នៅជាមួយគ្នា ពួកខ្លួនពុំមានភាពចុះសម្រុងនឹងគ្នា ធ្វើឲ្យពួកខ្លួនរស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀត ។

**៣. ចំណុចវិវាទ និងចំណុចគ្មានវិវាទ**

**៣.១. ចំណុចគ្មានវិវាទ៖** គ្មាន ។

**៣.២.ចំណុចវិវាទ៖**

១.ប្តឹងសុំលែងលះពីចុងចម្លើយឈ្មោះ [redacted] កុសល

២.សុំសិទ្ធិគ្រប់គ្រងកូនទាំងបីនាក់ ១.ឈ្មោះ [redacted] សុនិចាត់ ភេទប្រុស កើតថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០២ ២.ឈ្មោះ [redacted] សុជាតិ ភេទស្រី កើតថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៥ ៣ឈ្មោះ [redacted] បញ្ញាស័ក្តិ ភេទប្រុស កើតថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ។

៣.ប្តឹងសុំបែងចែកទ្រព្យសម្បត្តិរួមមាន៖

ក.ដីមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០២០៦-០០៤៣ ដែលមានទីតាំងនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

ខ.ដីដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០២០៦-០០៦៧ ដែលមានទីតាំងនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

គ. ដីដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលវត្ថុលេខ ០៨០១០២០៦-០០៦៨ ដែលមានទីតាំងនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

ឃ.ដីដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលវត្ថុលេខ ០៨០១០២៨០៤-០៤៥៣ ដែលមានទីតាំងនៅភូមិកំពង់ ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

ង.ដីដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលវត្ថុលេខ ០៨០១០២៨០៦-០១៤២ ដែលមានទីតាំងនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។



Scanned with CamScanner

៤.បំណុលរួមមានចំនួន ១៤៧.០០០ (ដប់បួនម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក ត្រូវទទួលខុសត្រូវពាក់កណ្តាលម្នាក់ ។

៥.បង្គាប់ឲ្យចុងចម្លើយប្រគល់នូវ ៖

ក.រថយន្តម៉ាក NEWFORD RANGER លេខតួ MNCUMFFSOKW941056 លេខម៉ាស៊ីន PSAT ២៧៤៦ ០៩៣ ពណ៌ស ម៉ូដែលឆ្នាំ២០១៩ ។

ខ.គ្រឿងចក្រម៉ាក CAterpilar e120Bលេខតួ ៧MF-០៤៩៦៦ លេខម៉ាស៊ីន ០០៨៧៩៣ ពណ៌លឿង

គ.គ្រឿងចក្រម៉ាកអ៊ិច សេរីឆ្នាំ២០០៧ លេខតួ 4SG07333 ពណ៌លឿង ។

ឃ.គ្រឿងចក្រម៉ាកអ៊ិច សេរីឆ្នាំ២០០៧ លេខតួ 7NF01064 ពណ៌លឿង ។

ង.រថយន្តម៉ាក lexus ពាក់ស្លាកលេខ ភ្នំពេញ 2AT-៤៧៨៣ ពណ៌សសេរីឆ្នាំ២០០៥

ជាទ្រព្យដោយឡែករបស់ខ្លួន ។

**៤.ការអះអាងរបស់ដើមចោទ**

ដើមចោទឈ្មោះ [redacted] វណ្ណរីនីត បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួនសូមរក្សាការទាមទារដូចមានក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នាថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៩ ទុកដដែល ។ ខ្លួនស្នើសុំលែងលះពីចុងចម្លើយឈ្មោះ [redacted] កុសល ដោយសារពួកខ្លួនអស់មនោសញ្ចេតនា ជាមួយគ្នាជាប្តីប្រពន្ធដោយ ពួកខ្លួនរស់នៅបែកគ្នាអស់រយៈពេល ០៣ ឆ្នាំមកហើយ ។ ក្នុងការរស់នៅជាមួយគ្នាមានកូនបីនាក់ ខ្លួនសុំសិទ្ធិគ្រប់គ្រងកូនទាំងបីនាក់ ១.ឈ្មោះ [redacted] សុធិ ថាត់ ភេទប្រុស កើតថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០២ ២ឈ្មោះ [redacted] សុជាតិ ភេទស្រី កើតថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៥ ៣ឈ្មោះ [redacted] បញ្ញាស័ក្តិ ភេទប្រុស កើតថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដោយខ្លួនពុំទាមទារអាហារកិច្ចចិញ្ចឹមកូននោះទេ ចំពោះទ្រព្យរួមមានដីមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០២០៦-០០៤៣ ដែលមានទីតាំងនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដីដែលមានវិញ្ញាបន បត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨០១ ០២០៦-០០៦៧ ដែលមានទីតាំងនៅភូមិកំពង់ទួល ឃុំ អន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដីដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០២០៦-០០៦៨ ដែលមានទីតាំងនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដីដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០ ២៨ ០៦-០១៤២ ដែលមានទីតាំងនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ខ្លួនស្នើសុំបែងចែកស្មើគ្នា ។ ចំពោះដីដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០ ២៨០៤-០៤៥៣ ដែលមានទីតាំងនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ខ្លួនសូមកែតម្រូវជាទ្រព្យដោយឡែកវិញ ខ្លួនស្នើសុំគ្រប់គ្រងលើដីនេះ។ ចំពោះបំណុលមានចំនួនសរុប ១៤៧.០០០ (ដប់បួនម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក ពួកខ្លួនខ្ចីពីធនាគារអេស៊ីលីដា,ធនាគារប្រៃសណីយ៍ និងធនាគារស្ថាបនា ខ្លួនស្នើសុំសងរួមគ្នា ។ ចំពោះទ្រព្យដោយឡែករបស់ខ្លួនមានរថយន្តម៉ាក NEWFORD RANGER លេខតួ MNCUMFFSOKW941056 លេខម៉ាស៊ីន PSAT ២៧៤ ៦០៩៣ ពណ៌សម៉ូដែលឆ្នាំ២០១៩ គ្រឿងចក្រម៉ាក CAterpilar e120Bលេខតួ ៧MF-០៤៩៦៦ លេខម៉ាស៊ីន ០០៨៧៩៣ ពណ៌លឿង គ្រឿងចក្រម៉ាកអ៊ិច សេរី ឆ្នាំ២០០៧ លេខតួ 4SG07333 ពណ៌លឿង គ្រឿងចក្រម៉ាកអ៊ិច សេរីឆ្នាំ ២០០៧ លេខតួ 7NF01064 ពណ៌លឿង ។ រថយន្តម៉ាក lexus ពាក់ស្លាកលេខ ភ្នំពេញ 2AT-៤៧៨៣ ពណ៌សសេរី ឆ្នាំ២០០៥ ខ្លួនសុំសិទ្ធិគ្រប់គ្រង ។

-ចុងចម្លើយឈ្មោះ [redacted] កុសល បានទទួលដីកាកោះចូលរួមក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ប៉ុន្តែអវត្តមានដោយគ្មានមូលហេតុ ។



Scanned with CamScanner

# សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរដើមចោទ

និងពិនិត្យភស្តុតាងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖

១.ចុងចម្លើយឈ្មោះ [redacted] កុសល មិនបានចូលរួមនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ តែដោយចុងចម្លើយបានទទួលដំណឹងពីកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់រួចហើយ ប៉ុន្តែចុងចម្លើយអវត្តមានដោយគ្មានមូលហេតុ។ ហេតុនេះសាលាដំបូងនឹងចេញសាលក្រមលើរឿងក្តីនេះ ជាសាលក្រមកំបាំងមុខចុងចម្លើយតាមមាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២.ដើមចោទឈ្មោះ [redacted] វណ្ណវីនីត បានធ្វើការអះអាងថាៈ ខ្លួនស្នើសុំលែងលះពីចុងចម្លើយឈ្មោះ [redacted] កុសល ដោយសារខ្លួនអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀត ហើយពួកខ្លួនរស់នៅបែកគ្នាអស់រយៈពេល ០៣ ឆ្នាំមកហើយ ។

៣.តាមសំបុត្រអាពាហ៍ពិពាហ៍លេខ ១២០៤០១០០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០១ អាចបញ្ជាក់បានថា ដើមចោទឈ្មោះ [redacted] វណ្ណវីនីត និងចុងចម្លើយឈ្មោះ [redacted] កុសល ពិតជាប្តីប្រពន្ធស្របច្បាប់ពោលគឺបំពេញលក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ដែលមានបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណី។

៤.អនុលោមតាមមាត្រា ៩៧៨ កថាខណ្ឌទី ១ ចំណុច ឃ នៃក្រមរដ្ឋប្បវេណី ចែងថា "ប្តី ឬប្រពន្ធអាចដាក់ពាក្យបណ្តឹងលែងលះគ្នាបាន ក្នុងករណីដែលកំណត់ខាងក្រោមនេះ៖ ឃ.បើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់អស់រយៈពេលជាង ១ (មួយ) ឆ្នាំ ផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍"។ ហេតុដូច្នេះគប្បីតុលាការសម្រេចតាមការទាររបស់ដើមចោទ។

៥.ដើមចោទឈ្មោះ [redacted] វណ្ណវីនីត បានស្នើសុំមានអំណាចមេបាលើកូនទាំងបី ១.ឈ្មោះ [redacted] សុនិ ថាត់ ភេទប្រុស កើតថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០២ ២ឈ្មោះ [redacted] សុជាតិ ភេទស្រី កើតថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៥ ៣ឈ្មោះ [redacted] បញ្ញាស័ក្តិ ភេទប្រុស កើតថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ។

៦.តាមសំបុត្រកំណើតលេខ ១៦៥ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៥ របស់កូនឈ្មោះ [redacted] សុនិថាត់ ,សំបុត្រកំណើតលេខ ១៩៩ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០៦ របស់កូនឈ្មោះ [redacted] សុជាតិ និងសំបុត្របញ្ជាក់កំណើតលេខ ៥១ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៧ របស់កូនឈ្មោះ [redacted] បញ្ញាស័ក្តិ អាចបញ្ជាក់បានថា ដើមចោទឈ្មោះ [redacted] វណ្ណវីនីត និងចុងចម្លើយឈ្មោះ [redacted] កុសល ពិតជាឪពុកម្តាយរបស់កូនទាំងបីប្រាកដមែន ។

៧.ដើមចោទស្នើសុំមានអំណាចមេបាលើកូនទាំងបីនាក់ ហេតុនេះតុលាការនឹងពិចារណាដោយសម្រេចតាមការទាមទាររបស់ដើមចោទ ។

៨.ដើមចោទឈ្មោះ [redacted] វណ្ណវីនីត បានស្នើសុំបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នា មានដីដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ០៨០១០២០៦-០១៤២ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៦,ដីដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០២០៦-០០៤៣ ដែលមានទីតាំងនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដីដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០២០៦-០០៦៧ ដែល មានទីតាំងនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដីដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលវត្ថុលេខ ០៨០១០២០៦-០០៦៨ ដែលមានទីតាំងនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។



Scanned with CamScanner

៩.តាមវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០២០៦-០១៤២ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៦ ដែលមានលិខិតកម្មសិទ្ធិ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១២ ,វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០២០៦-០១៤៣ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៦,វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០២០៦-០០៦៧ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៦ ដែលមានកិច្ចសន្យាលក់ផ្តាច់ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ និងកិច្ចសន្យាលក់ផ្តាច់ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៤,វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០២០៦-០០៦៨ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៦ ដែលមានកិច្ចសន្យាលក់ផ្តាច់ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ អាចបញ្ជាក់បានថា ដើមចោទឈ្មោះ [redacted] វណ្ណារីទិត និងចុងចម្លើយឈ្មោះ [redacted] កុសល ពិតជាម្ចាស់កម្មសិទ្ធិនៅលើដីទាំងបួនកន្លែងនោះប្រាកដមែន ។

១០.ដើមចោទឈ្មោះ [redacted] វណ្ណារីទិត ស្នើសុំបែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នា ហេតុនេះតុលាការនឹងពិចារណាតាមបញ្ញត្តិមាត្រា ៩៧៣ មាត្រា ៩៧៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ។

១១.ដើមចោទស្នើសុំគ្រប់គ្រងទ្រព្យសម្បត្តិដោយឡែក មានដីដែលមានវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨០១២៨០៤-០៤៥៣ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១១ ។ ហេតុនេះតុលាការនឹងពិចារណាផ្អែកតាមបញ្ញត្តិមាត្រា ៩៧២ មាត្រា ៩៨០ កថាខណ្ឌទី ២ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

១២.ដើមចោទទាមទារឱ្យបែងចែកបំណុលរួម មានចំនួន ១៤៧.០០០ (ដប់បួនម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក ដោយដើមចោទស្នើសុំបែងចែកជាពីរចំណែកស្មើគ្នា ដោយអះអាងថា ពួកខ្លួនបានខ្ចីប្រាក់ពីធនាគារស្ថាបនា ធនាគារអេស៊ីលីដា និងធនាគារប្រៃសណីយកម្ពុជា សរុបចំនួន ១៤៧០០០ (ដប់បួនម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក ។

១៣.តាមឯកសារភស្តុតាងដែលមានក្នុងសំណុំរឿង មានតារាងកាលវិភាគបង់ប្រាក់របស់ធនាគារស្ថាបនាភីអិលស៊ី តារាងកាលវិភាគសងប្រាក់ របស់ធនាគារអេស៊ីលីដា និងតារាងកាលវិភាគសងប្រាក់ របស់ធនាគារប្រៃ សណីយ តុលាការយល់ឃើញថា ដើមចោទឈ្មោះ [redacted] វណ្ណារីទិត និងចុងចម្លើយឈ្មោះ [redacted] កុសល ពិតជាបានខ្ចីប្រាក់ពីធនាគារទាំងបីប្រាកដមែន ។

១៤.ដើមចោទបានថ្លែងការណ៍ថា ចំពោះបំណុលរួមដែលខ្ចីពីធនាគារទាំងបី មានចំនួន ១៤៧០០០ (ដប់បួនម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក ប៉ុន្តែយោងតាមតារាងកាលវិភាគបង់ប្រាក់ របស់ធនាគារទាំងបី ឃើញថាបំណុលរួមមានចំនួនតែ ១១៣.២១៦ (ដប់មួយម៉ឺនបីពាន់ពីររយដប់ប្រាំមួយ)ដុល្លារអាមេរិក ។ ហេតុនេះតុលាការនឹងសម្រេចច្រានចោលការទាមទាររបស់ដើមចោទចំពោះបំណុលរួមចំនួន ១៤៧០០០ (ដប់បួនម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក ។

១៥.ដើមចោទឈ្មោះ [redacted] វណ្ណារីទិត បានថ្លែងការណ៍ថា ខ្លួនស្នើសុំគ្រប់គ្រងរថយន្តម៉ាក NEWFORD RANGER លេខតួ MNCUMFFSOKW941056 លេខម៉ាស៊ីន PSAT ២៧៤៦ ០៩៣ ពណ៌ស ម៉ូដែលឆ្នាំ២០១៩ ដែលជាទ្រព្យសម្បត្តិដោយឡែករបស់ខ្លួន ។

១៦.តាមវិក័យប័ត្រលេខ ០១៩៦៦៨ រវាងក្រុមហ៊ុន [redacted] និងដើមចោទឈ្មោះ [redacted] វណ្ណារីទិត បញ្ជាក់ថា ដើមចោទឈ្មោះ [redacted] វណ្ណារីទិត បានទិញរថយន្តនេះក្នុងចំណាងអាពាហ៍ពិពាហ៍ ហើយដើមចោទពុំមានឯកសារបញ្ជាក់ពីប្រភពនៃទ្រព្យសម្បត្តិដោយឡែក ដូចមានបញ្ញត្តិតាមមាត្រា ៩៧២ នៃក្រមរដ្ឋប្បវេណីឡើយ ។ ហេតុនេះតុលាការនឹងពិចារណាតាមបញ្ញត្តិមាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណី ។

១៧.ដើមចោទឈ្មោះ [redacted] វណ្ណារីទិត បានស្នើសុំគ្រប់គ្រងនូវគ្រឿងចក្រម៉ាក CAterpilar e120Bលេខតួ ៧MF-០៤៩៦៦ លេខម៉ាស៊ីន ០០៨៧៩៣ ពណ៌លឿង,គ្រឿងចក្រម៉ាកអ៊ិច សេរីឆ្នាំ២០០៧ លេខតួ 4SG07333 ពណ៌លឿង,គ្រឿងចក្រម៉ាកអ៊ិច សេរីឆ្នាំ២០០៧ លេខតួ 7NF01064 ពណ៌លឿង ដោយអះអាងថាជាទ្រព្យដោយឡែករបស់ខ្លួន ។



Scanned with CamScanner

១៨.តាមវិក័យប័ត្រលក់គ្រឿងចក្រលេខ ០០០១៥៣ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១០ ម៉ាក CAterpilar e120Bលេខតួ ៧MF-០៤៩៦៦ លេខម៉ាស៊ីន ០០៨៧៩៣ ពណ៌លឿង តុលាការយល់ឃើញថាជាទ្រព្យសម្បត្តិរួម ដែលបានទិញក្នុងចំណងអាពាហ៍ពិពាហ៍ ។ ហេតុនេះតុលាការគប្បីសម្រេចច្រានចោលការទាមទាររបស់ដើមចោទ ដោយសម្រេចបែងចែកគ្រឿងចក្រលេខ ០០០១៥៣ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១០ ម៉ាក CAterpilar e120Bលេខតួ ៧MF-០៤៩៦៦ លេខម៉ាស៊ីន ០០៨៧៩៣ ពណ៌លឿង ជាពីរចំណែកស្មើគ្នា ។

១៩.ចំពោះគ្រឿងចក្រម៉ាកអ៊ិច សេរីឆ្នាំ២០០៧ លេខតួ 4SG07333 ពណ៌ លឿង,គ្រឿងចក្រម៉ាកអ៊ិច សេរីឆ្នាំ២០០៧ លេខតួ 7NF01064 ពណ៌លឿង ពុំមានឯកសារភស្តុតាងបញ្ជាក់ពីកម្មសិទ្ធិរបស់សាមីភាគីឡើយ គប្បីតុលាការសម្រេចច្រានចោលការទាមទារ ។

២០.ដើមចោទឈ្មោះ [redacted] វណ្ណវីនីត បានស្នើសុំគ្រប់គ្រងទ្រព្យដោយឡែក មានរថយន្តម៉ាក lexus ពាក់ស្លាកលេខ ភ្នំពេញ 2AT-៤៧៨៣ ពណ៌សសេរី ឆ្នាំ២០០៥ ប៉ុន្តែដើមចោទពុំមានឯកសារភស្តុតាងបញ្ជាក់ពីកម្មសិទ្ធិលើរថយន្តនោះឡើយ ។ ហេតុនេះតុលាការនឹងសម្រេចច្រានចោលការទាមទាររបស់ដើមចោទ ។

២១.ប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## <u>សេចក្តីសម្រេចបញ្ចប់</u>

១/ឱ្យដើមចោទឈ្មោះ [redacted] វណ្ណវីនីត ភេទស្រី អាយុ ៣៩ ឆ្នាំ ជាតិខ្មែរ និងចុងចម្លើយ [redacted] កុសល ភេទប្រុស ជាតិខ្មែរ លែងលះគ្នាគិតចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ ។

២/កំណត់យកដើមចោទឈ្មោះ [redacted] វណ្ណវីនីត ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] សុនិថាត់ ភេទប្រុស កើតថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០២ ២. ឈ្មោះ [redacted] សុជាតិ ភេទស្រី កើតថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៥ ៣ឈ្មោះ [redacted] បញ្ញាស័ក្តិ ភេទប្រុស កើតថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ។

៣/បែងចែកទ្រព្យសម្បត្តិរួមជាពីរចំណែកស្មើគ្នាមាន៖

ក.ដីដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០២០៦-០០៤៣ ដែលមានទីតាំងនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

ខ.ដីដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ០៨០១០២០៦-០០៦៧ ដែលមានទីតាំងនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

គ.ដីដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់ អចលវត្ថុលេខ ០៨០១០២០៦-០០៦៨ ដែលមានទីតាំងនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្ត កណ្តាល ។

ឃ.ដីដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលវត្ថុលេខ ០៨០១០២៨០៦-០១៤២ ដែលមានទីតាំងនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។

៤/ប្រគល់ទ្រព្យសម្បត្តិដោយឡែកមានដីដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលវត្ថុលេខ ០៨០១០២៨០៤-០៤៥៣ ដែលមានទីតាំងនៅភូមិកំពង់ទួល ឃុំអន្លង់រមៀត ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ឱ្យទៅដើមចោទឈ្មោះ [redacted] វណ្ណវីនីត ជាអ្នកគ្រប់គ្រង ។

៥/ច្រានចោលការទាមទាររបស់ដើមចោទត្រង់ចំណុចទី៤ នៃពាក្យបណ្តឹង បំណុលរួមសរុប ១៤៧០០០ (ដប់បួនម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក ។



Scanned with CamScanner

៦/បង្គាប់ឲ្យដើមចោទឈ្មោះ [redacted] វណ្ណវិទិត និងចុងចម្លើយរួមគ្នាសងបំណុលរួមមានធនាគារស្ថាបនាភិវឌ្ឍន៍អេស៊ី ធនាគារប្រៃសណីយ និងធនាគារអេស៊ីលីដា ចំនួន ១១៣.២១៦ (ដប់មួយម៉ឺនបីពាន់ពីររយដប់ប្រាំមួយ)ដុល្លារអាមេរិក។

៧/ច្រានចោលការទាមទារត្រង់ចំណុចទី៥ ចំណុច ក និងចំណុច ខ នៃពាក្យបណ្តឹង

៨/បែងចែកជាពីរចំណែកស្មើគ្នានូវ ៖

៨.១.រថយន្តម៉ាក NEWFORD RANGER លេខតួ MNCUMFFSOKW941056 លេខម៉ាស៊ីន PSAT ២៧៤៦០៩៣ ពណ៌ស ម៉ូដែលឆ្នាំ២០១៩ ។

៨.២.គ្រឿងចក្រម៉ាក CAterpilar e120Bលេខតួ ៧MF-០៤៩៦៦ លេខម៉ាស៊ីន ០០៨៧៩៣ ពណ៌លឿង

៩/ច្រានចោលការទាមទារត្រង់ចំណុចទី ៥ ចំណុច គ.ឃ.ង នៃពាក្យបណ្តឹង ដែលស្នើសុំគ្រប់គ្រង គ្រឿងចក្រ ម៉ាកអ៊ិច សេរីឆ្នាំ២០០៧ លេខតួ 4SG07333 ពណ៌លឿង និងគ្រឿងចក្រម៉ាកអ៊ិច សេរីឆ្នាំ២០០៧ លេខតួ 7NF01064 ពណ៌លឿង និងរថយន្តម៉ាក lexus ពាក់ស្លាកលេខ ភ្នំពេញ 2AT-៤៧៨៣ ពណ៌សសេរី ឆ្នាំ២០០៥ ។

១០/ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

សាលក្រមនេះទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈនាថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ ចំពោះមុខដើមចោទ និងកំបាំងមុខចុងចម្លើយ ។

ចៅក្រម

ហត្ថលេខា និងត្រា៖ [redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ៤កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

កណ្តាល,ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០

បានឃើញ

ចៅក្រម

[redacted]

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner